## រឿងទី៤៖ ទូកណូអេ

**ខគម្ពីរ៖ លោកុប្បត្តិ៩៖១៦**

«ឥន្ទធនូនឹងស្ថិតនៅលើមេឃ ពេលណាយើងមើលឥន្ទធនូ យើងនឹងនឹកដល់សម្ពន្ធមេត្រីដ៏នៅស្ថិតស្ថេរជាអង្វែងតរៀងទៅ ជាសម្ពន្ធមេត្រីដែលព្រះជាម្ចាស់បានចងជាមួយសត្វលោកទាំងប៉ុន្មានដែលមានជីវិតរស់នៅលើផែនដី»។

កន្លងទៅអស់ពេលជាច្រើនឆ្នាំ តាំងពីអដាំនិងអេវ៉ានៅរស់ ចំនួនមនុស្សកាន់តែកើនឡើងច្រើនទៅៗនៅផែនដីនេះ។

ប៉ុន្តែ មនុស្សបានធ្វើឱ្យផែនដីនេះមានពេញដោយអំពើអាក្រក់ខ្លាំងពេក ធ្វើឱ្យព្រះជាម្ចាស់ទ្រង់ក្រោធជាខ្លាំង។

ប៉ុន្តែ នៅផែនដីនេះក៏មានមនុស្សល្អដែរ។ នោះគឺណូអេ។ ណូអេជាមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកជិតខាង។



គាត់តែងតែនៅជាប់ជាមួយព្រះជាម្ចាស់។ ថ្ងៃមួយ ព្រះជាម្ចាស់បានមានបន្ទូលបង្គាប់ណូអេឱ្យធ្វើទូកធំមួយ។

ណូអេបានចាប់ផ្តើមធ្វើទូកធំតាមការបង្គាប់របស់ព្រះជាម្ចាស់។

ណូអេធ្វើតាមអ្វីដែលព្រះជាម្ចាស់មានបន្ទូល ធ្វើទូកធំល្មមមួយអាចឱ្យសត្វញីឈ្មោលចូលទៅក្នុងនោះបាន។

សត្វគ្រប់ប្រភេទទាំងអស់បានចូលទៅក្នុងទូកធំនៅថ្ងៃដែលព្រះជាម្ចាស់ទ្រង់មានបន្ទូល។

មនុស្សដែលបានចូលទៅក្នុងទូកធំមានណូអេ និងភរិយា កូនប្រុសទាំងបីមានសិម ហាំ យ៉ាផេត និងកូនប្រសារបីនាក់ទៀត សរុបទាំងអស់មានតែចំនួនប្រាំបីនាក់ប៉ុណ្ណោះ។

ពេលទ្វារទូកធំត្រូវបានបិទភ្លាម ភ្លៀងក៏ចាប់ផ្តើមធ្លាក់មក។ ភ្លៀងធ្លាក់ខ្លាំងទាំងយប់ទាំងថ្ងៃឥតឈប់ឈរដូចគេហែកមេឃ។

ភ្លៀងចាប់ផ្តើមធ្លាក់អស់រយៈពេលសែសិបថ្ងៃ ហើយទីបំផុតភ្លៀងក៏ឈប់ធ្លាក់។

ថ្ងៃមួយ ណូអេ បានយកសត្វព្រាបមួយក្បាលមកព្រលែងវាទៅខាងក្រៅ ប៉ុន្តែដោយសារគ្មានកន្លែងទំ វាក៏ហើរត្រឡប់មកវិញ។

ប្រាំពីរថ្ងៃក្រោយ គាត់ក៏លែងសត្វព្រាបមួយទៅទៀត។ លើកនេះ សត្វព្រាបបានពាំស្លឹកអូលីវមកជាមួយ។

ធ្វើឱ្យណូអេដឹងថាទឹកបានស្រកពីផែនដីនេះហើយ។

កន្លងទៅបានបីរយចិតសិបថ្ងៃ ទឹកជំនន់ក៏បានស្រកអស់ពីផែនដី ពេលនោះ ព្រះជាម្ចាស់បានមានបន្ទូលទៅណូអេថា៖

«ណូអេអើយ ចូរនាំគ្រួសារអ្នក និងសត្វទាំងអស់ចេញពីក្នុងទូកធំនេះទៅ»

គ្រួសាររបស់ណូអេក៏បានចេញពីក្នុងទូកធំ។ ណូអេបានថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់ដើម្បីជាការអរព្រះគុណទ្រង់។

ព្រះជាម្ចាស់បានដាក់ឱ្យមានឥន្ទធនូដ៏ភ្លឺស្រស់ស្អាតនៅលើមេឃ។

ឥន្ទធនូនេះជា ៉សេចក្តីសញ្ញា៉របស់ព្រះជាម្ចាស់ ដែលបញ្ជាក់ថាទ្រង់នឹងមិនបំផ្លាញផែនដីដោយទឹកជំនន់ទៀតឡើយ។





**សកម្មភាពទី១** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



## សកម្មភាពទី២ សូមគូរភ្ជាប់រូបទូកធំណូអេ តាមលំដាប់លំដោយខាងក្រោម។


1
សូមកាត់ទូកធំណូអេ។


2
សូមកាត់បន្ទាត់ដែលបង្ហាញនៅកណ្តាលទឹករលក។


3
សូមបិទឈើនៅខាងក្រោយទូក។


4
សូមដាក់ទូកនៅកណ្តាលទឹករលក រួចធ្វើចលនាផ្លាស់ទី។





- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ៩៖១៦)

យើងនឹងនឹកដល់សម្ពន្ធមេត្រីដ៏នៅស្ថិតស្ថេរជាអង្វែងតរៀងទៅ